ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ខេត្តបាត់ដំបង ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីសំណេះសំណាល និងចុះសួរសុខទុក្ខរបស់អង្គភាពសម្ព័ន្ធមេត្រីភាពអគ្គនាយកដ្ឋានពន្ធដារ ជាមួយនាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន នៃទីបញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក ស្ថិតនៅភូមិសាស្ត្រ ភូមិឥន្ទជិត ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង

ថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ខេត្តបាត់ដំបង ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃអង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ មានរៀបចំពិធីសំណេះសំណាល និងសាកសួរសុខទុក្ខយុទ្ធជន ជានាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន នៃទីបញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក ដែលមានភូមិសាស្ត្រ ស្ថិតនៅភូមិឥន្ទជិត ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ក្រោមអធិបតីភាពឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គនាយក នៃ អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច នៃក្រសួងការពារជាតិ និងបាន



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

ពាំនាំនូវការផ្ដាំផ្ញើសួរសុខទុក្ខ និងអំណោយដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដើម្បីចែកជូនដល់បងប្អូនយុទ្ធជន ដែលជានាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន។

ជាមួយគ្នានេះ ពិធីសំណេះសំណាលនេះគឺជាការសួរសុខទុក្ខមុនពិធីបុណ្យភ្ជុំបិណ្ឌ ដើម្បីឆ្លៀតឱកាសអបអរសាទរ និងជូនពរដល់បងប្អូនយុទ្ធជន ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ដែលនឹងឈានចូលមកដល់នាថ្ងៃពុធ ១៤រោច ខែភទ្របទ ឆ្នាំជូតទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញាខាងមុខនេះ។ ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលក៏បានគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដែលបានផ្ដល់ការទុកចិត្ត និងបានអនុញ្ញាត ឱ្យអគ្គនាយកដ្ឋានពន្ធដារចងសម្ព័ន្ធមេត្រីភាពជាមួយនឹងកងទ័ព កងពលរថក្រោះ ដែលឈរជើងបំពេញភារកិច្ចយ៉ាងម៉ឺងម៉ាត់ក្នុងការងារការពារអធិបតេយ្យ និងបូរណភាពទឹកដី ក៏ដូចជាចូលរួមចំណែក រក្សានូវស្ថិរភាព និងសុខសន្តិភាពជូនប្រជាជនកម្ពុជា។ ក្នុងឱកាសនេះដែរ ឯកឧត្តមប្រតិភូរាជរដ្ឋា-ភិបាលបានគូសបញ្ជាក់ថា ខណៈដែលបងប្អូនជាយុទ្ធជនយើងកំពុងបម្រើការនៅសមរភូមិមុខ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងបំពេញតួនាទីរបស់ខ្លួនជាអង្គភាព នៅសមរភូមិខាងក្រោយក្នុងការខិតខំប្រមូលចំណូលជូនជាតិ តាមរយៈការធ្វើកំណែទម្រង់និងទំនើបកម្មឥតឈប់ឈរ ដើម្បីបម្រើដល់តម្រូវការរបស់ប្រទេសជាតិ ក្នុងនោះរួមមានថវិកាដែលបើកជូនដល់បងប្អូនជាកងទ័ពផងដែរ តាមរយៈក្រសួងការពារជាតិ។ លទ្ធភាពនៃការប្រមូលចំណូលពន្ធ ដែលអាចធ្វើទៅបានក៏ដោយសារប្រទេសជាតិយើង មានសុខសន្តិភាព ស្ថិរភាព និងមានការរីកចម្រើនឥតឈប់ឈរ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានរំលឹកដល់បងប្អូនយុទ្ធជន សូមរក្សាឱ្យបាននូវគោលជំហរ និងស្មារតីស្នេហាជាតិមោះមុត និងការពារឱ្យបានជាដាច់ខាតនូវរាជរដ្ឋាភិបាលស្របច្បាប់ ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិត របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដែលបាននិងកំពុងអភិវឌ្ឍន៍ប្រទេសជាតិយ៉ាងសកម្ម ព្រមទាំងមានការគិតគូរជាពិសេស ដល់បងប្អូនជាយុទ្ធជន តាមរយៈការដំឡើងនូវប្រាក់បៀវត្សជាបន្តបន្ទាប់។ ជាក់ស្ដែង ដូចការដែលបានសន្យា ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានដំឡើងប្រាក់បៀវត្សយោធា (កងទ័ព) ខណៈដែលបៀវត្សដែលកើនឡើងនេះ មិនស្ថិតក្នុងពិតានជាប់ពន្ធលើប្រាក់បៀវត្សផងដែរ ក្នុងគោលដៅចូលរួមចំណែកលើកកម្ពស់កម្រិតជីវភាពរបស់បងប្អូនជាយុទ្ធជន ឱ្យកាន់តែមានជីវភាពធូរធារ ក៏ដូចជាការសបញ្ជាក់អំពីលទ្ធភាព ក្នុងការធ្វើឱ្យមានភាពប្រាកដនិយមតាមការសន្យា ដែលមិនមែនការសន្យាខ្យល់នោះទេ។

នៅក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ប្រពៃណីជាតិនាពេលខាងមុខ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានផ្ដាំផ្ញើនូវការសាកសួរសុខទុក្ខ និងក្រើនរំលឹកឱ្យយុទ្ធជនយើងបន្តពង្រឹងការការពារក្នុងស្មារតីប្រុងប្រយ័ត្នខ្ពស់ កុំឱ្យមានការឆ្លងរាលដាលនូវជំងឺកូវីដ-១៩ តាមរយៈឯកឧត្តម **គង់ វិបុល** ប្រតិភូរាជ-រដ្ឋាភិបាល និងឯកឧត្តម ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** ដោយបានផ្ដល់ជូនអំណោយជាសម្ភារ គ្រឿងឧបភោគបរិភោគ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

និងភេសជ្ជៈ ព្រមទាំងថវិកាមួយចំនួន ដើម្បីជួយឧបត្ថម្ភនិងចែកជូនដល់នាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន នៃទីបញ្ជាការដ្ឋានរថក្រោះ កងទ័ពជើងគោក ដែលកំពុងបំពេញការងារយ៉ាងសកម្ម ក្នុងបុព្វហេតុការពារជាតិ។

ជាកិច្ចបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀត ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាយទាហាន នាយទាហានរង ពលទាហាន គ្រួសារកងទ័ព និងនិវត្តជន ទាំងអស់ និងសូមជូនពរសូមជូនពរឆ្នាំថ្មីប្រពៃណីជាតិ ឱ្យសមប្រកបនឹងពុទ្ធពរទាំង ៤ ប្រការគឺអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ